01303886

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 07 / 2016
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E394/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី១១ ខែ កក្កដា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រី និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកជាឯកសារភ័ស្តុតាងនូវរូបថត ដែលបានកំណត់អត្តសញ្ញាណថាជារូបថត ថតនៅមន្ទីរសន្តិសុខ ស-២១ នៅក្នុងបញ្ជីពាក់ព័ន្ធដែលត្រូវបានទទួលយក E3/9214

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលបានដាក់ដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ("សំណើ" ឯកសារ E394) អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកជាភ័ស្តុតាងនូវរូបថតជាច្រើនដែលត្រូវបានអះអាងថាថតនៅមន្ទីរសន្តិសុខ ស-២១ (ឯកសារ E394.1)។ នៅក្នុងអំឡុងពេលសវនាការថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកជាឯកសារភ័ស្តុតាងនូវរូបថតដែលបានស្នើឡើង ដោយសំអាងហេតុនឹងចេញនៅពេលក្រោយ (ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៤៤-៤៥)។ ភាគីដទៃទៀត មិនបានជំទាស់ទៅនឹងការទទួលយករូបថតទាំងនេះទេ (ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៤៥-៤៦)។ នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងផ្ដល់នូវសំអាងហេតុចំពោះការទទួលយករូបថតទាំងនោះ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងទាំងអស់ ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ក្នុងករណីដែលភស្តុតាងនោះបំពេញបទដ្ឋាន *បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលបានស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលខ្លួនស្នើសុំដាក់នោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ឬ ពុំអាចត្រូវបានរកឃើញទោះបីជាបានខិតខំព្យាយាមយ៉ាងសមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំង ក្នុងករណីដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និងករណីដែលឯកសារដែលបានស្នើសុំដាក់នេះ គឺជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E276/2 កថាខណ្ឌ ២ យោងទៅលើឯកសារ E190 និង E172/24/5/1, ឯកសារ E260 កថាខណ្ឌ ៥)។

៣. អង្គជំនុំជម្រះយល់ឃើញថា ទោះបីជារូបថតទាំងនេះ ដូចជាត្រូវបានបន្សល់ទុកពីសម័យកាលកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏រូបថតដែលបានស្នើសុំឱ្យទទួលយកទាំងនេះ មិនអាចរកបានដើម្បីដាក់ចូលក្នុងសំណុំរឿង មុនពេលចាប់ផ្តើមការជំនុំជម្រះឡើយ ហើយថា សហព្រះរាជអាជ្ញាបានខិតខំប្រឹងប្រែងយ៉ាងសមស្របក្នុងការដាក់សំណើនេះនៅក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីទទួលបានសំណៅថតចម្លងរូបថតទាំងនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E394 កថាខណ្ឌ ២-៣)។ ជាពិសេស សហព្រះរាជអាជ្ញា បានដាក់បញ្ចូលសេចក្តីយោងមួយទៅលើរូបថតទាំងនេះនៅក្នុងបញ្ជីឯកសាររបស់ខ្លួនសម្រាប់សំណុំរឿង ០០២ ដោយបានបញ្ជាក់ថា រូបថតទាំងនេះមិនទាន់អាចរកបានឡើយនៅពេលនោះ (ឯកសារ E305/13.23 លេខរៀង ៦៦) ហើយសន្ទស្សន៍លម្អិតនៃរូបថតទាំងនេះត្រូវបានទទួលយកជាឯកសារ E3/9214។ អង្គជំនុំជម្រះកត់សម្គាល់ថា រូបថតទាំងនេះបង្ហាញអំពីបុគ្គលជាច្រើនដែល

ជាក់ស្តែងត្រូវបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ និងមានចំណារសរសេរដោយដៃផង ដែរ។ រូបថតទាំងនេះបំពេញតាមបទដ្ឋាន*បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព។ បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះយល់ឃើញថា រូបថតទាំងនេះពាក់ព័ន្ធយ៉ាង ជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅក្នុងសំណុំរឿង ជាពិសេស ឯកសារ E3/9214 ដែលជាសន្ទស្សន៍លម្អិតនៃរូបថតទាំងនេះ។ ដូច្នេះ អង្គជំនុំជម្រះទទួលយករូបថតទាំងនេះជា ឯកសារភ័ស្តុតាង និងដាក់លេខឯកសារ E3/9214a។

៤. នេះជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E394។